ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ១២៤៣ មស.សរ

**សារាចរណែនាំរួម**
**រវាងក្រសួងមុខងារសាធារណៈនិងក្រសួងសុខាភិបាល**
**ស្តីពី**
**ការធ្វើបច្ចុប្បន្នភាពស្ថានភាពរដ្ឋបាលលើតារាងបៀវត្សប្រចាំខែ**
**មន្ត្រីរាជការនៃក្រសួងសុខាភិបាល**

ដើម្បីគ្រប់គ្រងមន្ត្រីរាជការឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រួមទាំងជំនាញនិងចំនួនឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតប្រាកដ ស្របតាមកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈបាននឹងកំពុងសហការជាមួយក្រសួងសុខាភិបាល និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ក្រសួងសុខាភិបាល។ ការធ្វើវិមជ្ឈការប្រព័ន្ធគ្រប់គ្រងនេះដល់ក្រសួងសុខាភិបាល គឺដើម្បីផ្តល់ភាពជាម្ចាស់និងការទទួលខុសត្រូវពិតប្រាកដលើការគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាដូចជា៖ (១)ការបញ្ចូល ការប្រើប្រាស់និងការធ្វើបច្ចុប្បន្នភាពទិន្នន័យ (២)ការគ្រប់គ្រងនិងអភិវឌ្ឍផែនការធនធានមនុស្ស (៣)ការផលិតតារាងទូទាត់បៀវត្សអេឡិចត្រូនិច និងព័ត៌មានផ្សេងៗទៀតតាមតម្រូវការជាដើម។

មុននឹងការប្រកាសដាក់ឲ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ក្រសួងសុខាភិបាលជាផ្លូវការ ក្រសួងមុខងារសាធារណៈនិងក្រសួងសុខាភិបាលបានឯកភាពគ្នាចេញសារាចរណែនាំដល់បណ្តាអង្គភាពក្រោមឱវាទរបស់ខ្លួនអនុវត្តដូចខាងក្រោម៖

១-គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវធ្វើបច្ចុប្បន្នភាពតារាងទូទាត់បៀវត្សលើស្ថានភាពរដ្ឋបាលមន្ត្រីរាជការរបស់អង្គភាពខ្លួនទៅតាមរចនាសម្ព័ន្ធដែលមានជាក់ស្តែងដោយ៖

- កំណត់ឈ្មោះអង្គភាពមូលដ្ឋានសុខាភិបាលឱ្យបានច្បាស់លាស់
- បញ្ចូលឱ្យអស់នូវអង្គភាពដែលបានបង្កើតថ្មីទៅក្នុងតារាងទូទាត់បៀវត្សដោយរៀបចំតាមរចនាសម្ព័ន្ធដែលមានស្រាប់ ដើម្បីផ្តល់ភាពងាយស្រួលដល់ការពិនិត្យផ្ទៀងផ្ទាត់មន្ត្រីរាជការដែលកំពុងបម្រើការងារក្នុងអង្គភាពជាក់ស្តែង
- រៀបចំស្ថានភាពមន្ត្រីរាជការទៅក្នុងប្រអប់អង្គភាពដែលបានកំណត់រួចហើយ ទៅតាមទីកន្លែងដែលមន្ត្រីសាមីនោះកំពុងបម្រើការងារជាក់ស្តែង
- លើកសំណើសុំក្រសួងមុខងារសាធារណៈ តាមរយៈមន្ទីរមុខងារសាធារណៈ ធ្វើការកែតម្រូវស្ថានភាពមន្ត្រីទៅក្នុងតារាងបៀវត្ស តាមសភាពជាក់ស្តែងដែលបានរៀបចំហើយដូចខាងលើ ឱ្យបានត្រឹមត្រូវនិងឆាប់រហ័ស

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

- តម្រូវឱ្យធ្វើបច្ចុប្បន្នភាពស្ថានភាពរដ្ឋបាលលើតារាងបៀវត្សប្រចាំខែនេះឱ្យបានចប់ជាស្ថាពរ ក្នុងរយៈពេល៣ខែគិតចាប់ពីខែមេសាដល់ខែមិថុនាឆ្នាំ២០១៨ ជាកំហិត ។

២-គ្រប់មន្ទីរមុខងារសាធារណៈរាជធានី-ខេត្ត មានភារកិច្ចសហការ សម្របសម្រួល និងជួយដល់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្នុងការធ្វើបច្ចុប្បន្នភាពស្ថានភាពរដ្ឋបាលលើតារាងបៀវត្សប្រចាំខែរបស់មន្ត្រីសុខាភិបាលនេះឱ្យមានភាពរលូន និងទទួលបានជោគជ័យទាន់ពេលវេលា ។

៣-គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវផ្អាកជាកំហិតរាល់ការអនុញ្ញាតឱ្យមន្ត្រីរាជការផ្ទេរចេញ ឬ ផ្ទេរចូលតាមគ្រប់រូបភាពទាំងក្នុងរាជធានី-ខេត្ត និងទាំងឆ្លងរាជធានី-ខេត្ត ក្នុងរយៈពេលនៃការធ្វើបច្ចុប្បន្នភាពតារាងទូទាត់បៀវត្សនេះ។

៤-គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្តនិងអង្គភាពក្រោមឱវាទទាំងអស់ ដែលមានមន្ត្រីរាជការបានផ្ទេរចេញ ឬ ចូលឆ្លងខេត្តពីមុនមក ហើយបច្ចុប្បន្នប្រាក់បៀវត្សរបស់សាមីជនមិនទាន់បានផ្តាច់ ឬ បញ្ចូលទៅតាមទីកន្លែងកំពុងបម្រើការងារនោះទេ ត្រូវធ្វើឱ្យបានរួចរាល់ក្នុងរយៈពេលនៃការធ្វើបច្ចុប្បន្នភាពតារាងទូទាត់បៀវត្សនេះ។

៥-គ្រប់មន្ទីរមុខងារសាធារណៈរាជធានី-ខេត្ត និងគ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវសហការរួមគ្នាអនុវត្ត និងរួមគ្នាដោះស្រាយរាល់បញ្ហាដែល កើតមានដើម្បីសម្រេចឲ្យបានទាន់ពេលវេលាកំណត់នូវការធ្វើបច្ចុប្បន្នភាពតារាងបៀវត្សមួយមានលក្ខណៈត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់មន្ត្រីដែលកំពុងបំពេញការងារតាមអង្គភាពនីមួយៗ។ ក្នុងករណីដែលមិនអនុវត្តតាមសារាចរណែនាំនេះនឹងត្រូវទទួលវិធានការខាងវិន័យតាមផ្លូវច្បាប់ជាធរមាន។

ទទួលបានសារាចរណែនាំរួមនេះគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមុខងារសាធារណៈនិងក្រសួងសុខាភិបាល ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហ ៥កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល** **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

ម៉ម ប៊ុនហេង ពេជ្រ ប៊ុនធិន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលារាជធានី-ខេត្ត

"ជូនជ្រាប"
- ឯកសារ-កាលប្បវត្ត